នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 13-Jun-2012, 14:38
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

# សំណើសុំសិទ្ធិផ្តល់ឯកសារក្នុងសំណុំរឿង ០០២ ដល់សាក្សីជំនាញ

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**

ជនជាប់ចោទ:
នួន ជា
អៀង សារី
ខៀវ សំផន

មេធាវីការពារក្តីជនជាប់ចោទ:
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe
លោក អាង ឧត្តម
លោក Michael G.KARNAVAS

លោក គង់ សំអុន
Anta GUISSÉ
លោក Arthur VERCKEN
លោក Jacques VERGÈS

# សំណើ

១- នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញដីកាសម្រេចមួយ[1] ដោយអញ្ជើញភាគីឲ្យផ្ដល់នូវលក្ខណៈពិសេសបន្ថែម អំពីវិសាលភាពនៃការសួរសំណួរដែលខ្លួនមានបំណងសួរចំពោះអ្នកជំនាញ។ អនុលោមតាមដីកាសម្រេចនោះ សហព្រះរាជអាជ្ញាបានដាក់អនុស្សរណៈមួយជូនទៅអង្គភាពគាំពារសាក្សី និងអ្នកជំនាញ(WESU)[2] ដោយមានភ្ជាប់ទៅជាមួយនូវលិខិតមួយចំនួនដែលនឹងត្រូវផ្ញើទៅឲ្យអ្នកជំនាញម្នាក់ៗ ដែលនៅក្នុងលិខិតនោះផ្ដល់ជូននូវបញ្ជីប្រធានបទដែលអាចនឹងត្រូវសួរចំពោះអ្នកជំនាញទាំងនោះ ក្នុងអម្លុងពេលនៃការស្ដាប់សក្ខីកម្មរបស់ពួកគាត់។

២- សន្និដ្ឋានថា អ្នកជំនាញនឹងអាចផ្ដល់សក្ខីកម្មបានយ៉ាងល្អ បើសិនគាត់មានលទ្ធភាពពិនិត្យ និងពិចារណាទៅលើជម្រើសឯកសារពាក់ព័ន្ធមួយចំនួន រួមទាំងឯកសារសម្ងាត់ដែលមាននៅក្នុងសំណុំរឿង០០២។ តាមពិតកន្លងមកអ្នកជំនាញធ្លាប់បានពិនិត្យមើលឯកសារជាច្រើន ក្នុងការស្រាវជ្រាវសៀវភៅដែលគាត់បានសរសេរ។ ប៉ុន្តែភាគច្រើននៃសៀវភៅទាំងនេះ បានសរសេរជាច្រើនឆ្នាំកន្លងមក ហើយយើងរំពឹងថាអ្នកជំនាញទាំងនោះនឹងបានទទួលផលប្រយោជន៍ពីការផ្ដល់ឱកាស ដើម្បីពិនិត្យឡើងវិញទៅលើជម្រើសឯកសារមួយចំនួនក្នុងសំណុំរឿង០០២ ដើម្បីវាយតម្លៃឡើងវិញ និងធ្វើឲ្យកាន់តែប្រសើរឡើងចំពោះសេចក្ដីថ្លែងការណ៍ណាមួយ ដែលបានសរសេរក្នុងសៀវភៅរបស់គាត់។

៣- ជាលទ្ធផល សហព្រះរាជអាជ្ញាស្នើដល់អង្គជំនុំជម្រះសាលាដំបូង ផ្ដល់សិទ្ធិឲ្យសហព្រះរាជអាជ្ញាដើម្បីបញ្ចេញទៅឲ្យអ្នកជំនាញនូវជម្រើសឯកសារសម្ងាត់ដែលមាននៅក្នុងសំណុំរឿង០០២ បើសិនសហព្រះរាជអាជ្ញាយល់ថាចាំបាច់។ ឯកសារដូច្នេះអាចរួមបញ្ចូលប្រភេទឯកសារដូចខាងក្រោម៖ ការបោះពុម្ពផ្សាយ និងសារាចរណែនាំរបស់ បកក (រួមមាន ទស្សនាវដ្ដីទង់បដិវត្ត) កំណត់ហេតុប្រជុំរបស់គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ ឯកសារអំពីការប្រាស្រ័យទាក់ទងរបស់កម្ពុជាប្រជាធិបតេយ្យ សេចក្ដីថ្លែងការណ៍ជាសាធារណៈ និងសេចក្ដីថ្លែងការណ៍តាមប្រព័ន្ធឃោសនាព័ត៌មានរបស់កម្ពុជាប្រជាធិបតេយ្យ ប្រវត្តិរូបរបស់កម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុពាណិជ្ជកម្ម

---

[1] **E172/24**, ដីកាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា ព័ត៌មានបច្ចុប្បន្នភាពទាក់ទិននឹងការកំណត់កាលបរិច្ឆេទសាក្សីអ្នកជំនាញដែលបានស្នើសុំ, ២៥ ឧសភា ២០១២។

[2] អនុស្សរណៈអន្តរការិយាល័យដែលមានចំណងជើងថា ព័ត៌មានបន្ថែមនឹងត្រូវផ្ដល់ជូនដល់អ្នកជំនាញ David Chandler, Philip Short, Elizabeth Becker និង Henri Locard, ៤ មិថុនា ២០១២។

របស់កម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុស្រុកត្រាំកក់ កំណត់ហេតុរបស់អ្នកទោសស-២១ ចម្លើយសារភាពស-២១ និងប្រតិចារឹកនៃភ័ស្តុតាងក្នុងចំណោមប្រភេទឯកសារផ្សេងៗទៀត។

៤- ប្រសិនបើ អង្គជំនុំជម្រះសាលាដំបូងផ្តល់សិទ្ធិឲ្យបញ្ចេញឯកសារផ្សេងៗទៅឲ្យអ្នកជំនាញ នោះសហព្រះរាជអាជ្ញាត្រូវបំពេញកិច្ចៈ

១) រក្សាទុកកំណត់ហេតុនៃឯកសារទាំងអស់ដែលបានផ្តល់ជូនអ្នកជំនាញទាំងនោះ;

២) ធានាឲ្យប្រាកដថា លិខិតធានាសមស្របនឹងត្រូវផ្តល់ជូនដល់អ្នកជំនាញទាំងនោះ ទាក់ទិននឹងភាពសម្ងាត់; និង

៣) ធានាឲ្យប្រាកដថា ឯកសារនោះនឹងប្រគល់មកវិញ និងមិនត្រូវបានថតចម្លង ឬរក្សាទុកដោយអ្នកជំនាញទាំងនោះឡើយ។

៥- ដោយសារការស្តាប់សក្ខីកម្មរបស់អ្នកជំនាញទីមួយត្រូវបានកំណត់កាលបរិច្ឆេទរួចហើយនៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១២ សហព្រះរាជអាជ្ញាស្នើឲ្យមានសេចក្តីសម្រេចមួយលើសំណើសុំនេះ ឲ្យបានឆាប់តាមដែលអាចធ្វើបាន ដើម្បីអនុញ្ញាតឲ្យមានពេលវេលាជាអតិបរមា សម្រាប់អ្នកជំនាញរូបនេះ ពិនិត្យឡើងវិញទៅលើជម្រើសឯកសារ បើសិនជាចាំបាច់៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១២ | **លោកស្រី ជា លាង** សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** William SMITH សហព្រះរាជអាជ្ញារង | | [signature] |